# រដ្ឋលេខាធិការ

សួស្តីអ្នកបោះឆ្នោតជាទីរាប់អាន៖

តាមរយៈការចុះឈ្មោះបោះឆ្នោត អ្នកបានបោះជំហានដំបូងក្នុងការ ដើរតួនាទីដ៏សកម្មមួយក្នុងការកំណត់អនាគត របស់រដ្ឋកាលីហ្វ័រញ៉ា។ ឥឡូវនេះ ដើម្បីជួយឲ្យអ្នកធ្វើការសំរេចចិត្តរបស់អ្នក ការិយាល័យរបស់ខ្ញុំបានបង្កើតនូវកំរងណែនាំព័ត៌មានអ្នកបោះឆ្នោតជាផ្លូវការ – គឺគ្រាន់តែជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ដែលមានប្រយោជន៍ជាច្រើនសំរាប់ការរៀនបន្ថែមអំពីអ្វីដែលនឹងមានដាក់នៅលើសន្លឹកឆ្នោតរបស់អ្នកនិងអំពីរបៀបប្រព្រឹត្តទៅនៃការបោះឆ្នោតនេះ។ ព័ត៌មានអំពីបេក្ខជននិងវិធានការសំរាប់តែតំបន់របស់អ្នក គឺអាចរកឃើញនៅក្នុងកូនសៀវភៅបោះឆ្នោតគំរូ សំរាប់តំបន់របស់អ្នក។ ហើយសំរាប់ព័ត៌មានលំអិតបន្ថែមទៀតសំរាប់ដំណើរការបោះឆ្នោត – រួមមានរបៀបពិនិត្យ ស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក កន្លែងទៅបោះឆ្នោត ឬក៏ថាតើសន្លឹកឆ្នោតដែលបោះតាមសំបុត្រត្រូវបានទទួល ឬទេ – សូមចូលមើលក្នុងគេហទំព័រ *www.sos.ca.gov/elections* ឬទូរស័ព្ទមកលេខ (888) 345-4917។

ការបោះឆ្នោតគឺងាយស្រួល ហើយរាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះ មានជំរើសបោះឆ្នោតតាមសំបុត្រឬនៅ តាមកន្លែងបោះឆ្នោតនៅក្នុងតំបន់។ ថ្ងៃចុងក្រោយដើម្បីស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្រពីការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកគឺថ្ងៃទី 30 ខែតុលា។ នៅថ្ងៃបោះឆ្នោត មន្ទីរបោះឆ្នោតទាំងឡាយ បើកទ្វារចាប់ពីម៉ោង 7:00 ព្រឹក ដល់ ម៉ោង 8:00 យប់។

មានជំរើសជាច្រើនដើម្បីចូលរួមនៅក្នុងដំណើរការបោះឆ្នោត។

- ធ្វើជាអ្នកធ្វើការនៅមន្ទីរបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដោយជួយឲ្យការបោះឆ្នោតមានភាពងាយស្រួលសំរាប់អ្នកបោះឆ្នោតដែលមានសិទ្ធិទាំងអស់ និងការពារសន្លឹកឆ្នោតរហូតដល់បានរាប់ដោយមន្ត្រីបោះឆ្នោត។
- ផ្សព្វផ្សាយនូវពាក្យអំពីកាលកំណត់ការចុះឈ្មោះអ្នកបោះឆ្នោតនិងសិទ្ធិបោះឆ្នោតតាមរយៈអ៊ីម៉េល ទូរស័ព្ទ កូនសៀវភៅព័ត៌មាន និងប័ណ្ណប្រកាស។
- ជួយអប់រំអ្នកបោះឆ្នោតផ្សេងទៀតអំពីបេក្ខជនឈរឈ្មោះនិងបញ្ហានានា ដោយរៀបចំក្រុមពិភាក្សាឬចូលរួមក្នុងការពិភាក្សាវែកញែកជាមួយមិត្តភក្តិ គ្រួសារ និងមេដឹកនាំសហគមន៍។

សៀវភៅមគ្គុទ្ទេសក៍ណែនាំនេះមានចំណងជើងនិងសេចក្តីសង្ខេបនៃវិធានការឆ្នោតរបស់រដ្ឋដែល រៀបចំដោយអគ្គមេធាវី Kamala D. Harris ការវិភាគដោយមិនលំអៀងនៃវិធានការ ឆ្នោតនិងសក្តានុពលនៃថ្លៃ ចំណាយដែលអាច កើតមានចំពោះអ្នកបង់ពន្ធដែលរៀបចំដោយអ្នកវិភាគនិតិបញ្ញត្តិ Mac Taylor ទឡ្ហីករណ៍គាំទ្រ និងប្រឆាំងវិធានការឆ្នោតដែលរៀបចំដោយអ្នកគាំទ្រនិងអ្នកប្រឆាំង អត្ថបទនៃ សំណើច្បាប់ដែលរៀបចំនិងពិនិត្យមើលដោយ មេធាវីនិតិបញ្ញត្តិ Diane F. Boyer-Vine និងព័ត៌មានមានប្រយោជន៍ផ្សេងទៀត។ ការបោះពុម្ពនូវសៀវភៅណែនាំ នេះត្រូវបានធ្វើឡើងនៅក្រោមការត្រួតពិនិត្យរបស់អ្នកបោះពុម្ពរបស់រដ្ឋស្តីទី Kevin P. Hannah។

វាជាសិទ្ធិដ៏អស្ចារ្យមួយក្នុងលទ្ធិប្រជាធិបតេយ្យក្នុងការមានជំរើសមួយនិងសិទ្ធិបញ្ចេញមតិរបស់អ្នក។ ដូចដែលអ្នក ដឹងហើយការប្រកួតប្រជែងខ្លះពិតជាប្រជិតប្រជើយមែនទែនគឺគ្រាន់តែឃ្លាតគ្នាតែពីរបីសំឡេងប៉ុណ្ណោះ។ ខ្ញុំសូម លើកទឹកចិត្តអ្នកឲ្យចំណាយពេលអានអំពីបេក្ខជនមួយរូបៗនិងវិធានការឆ្នោតដោយយកចិត្តទុកដាក់ – និង ដើម្បី ដឹងពីសិទ្ធិបោះឆ្នោតរបស់អ្នក។

សូមអរគុណសំរាប់ការប្រកាន់ខ្ជាប់នូវករណីយកិច្ចជាពលរដ្ឋយ៉ាងយកចិត្តទុកដាក់របស់អ្នកនិងការធ្វើឲ្យសំឡេងរបស់អ្នកបានឮ!